**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
លេខ ០៨៧ ព.ណ.[illegible]

# សេចក្តីសម្រេច
## ស្តីពី
## លក្ខខណ្ឌនិងនីតិវិធីនៃការស្នើសុំការអនុញ្ញាតលើកលែង ក្រោមច្បាប់ស្តីពីការប្រកួតប្រជែង

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជាប្រធានគណៈកម្មាធិការប្រកួតប្រជែងកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០២១/០១៣ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រកួតប្រជែង
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ៣៧ អនក្រ.បក ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការប្រកួតប្រជែងកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៦០ អនក្រ.បក ចុះថ្ងៃទី៦ ខែមីនា ឆ្នាំ២០២៣ ស្តីពីលក្ខខណ្ឌនិងនីតិវិធីអំពីការរួមបញ្ចូលគ្នានៃធុរកិច្ច
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-** គោលបំណង

សេចក្តីសម្រេចនេះ កំណត់អំពីលក្ខខណ្ឌនិងនីតិវិធីនៃការស្នើសុំការអនុញ្ញាតលើកលែងក្រោមច្បាប់ស្តីពីការប្រកួតប្រជែង ដោយគណៈកម្មាធិការប្រកួតប្រជែងកម្ពុជា «គ.ប.ក.» ចំពោះការព្រមព្រៀងឬសកម្មភាពណាមួយដែលអាចរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែង។



១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
លេខទំនាក់ទំនង៖ ១៦៦៦
អ៊ីម៉ែល៖ cabinet.info@moc.gov.kh

**ប្រការ២.- វិសាលភាព**

សេចក្តីសម្រេចនេះ មានវិសាលភាពអនុវត្តចំពោះការព្រមព្រៀងឬសកម្មភាពណាមួយដែលអាចរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែងក្នុងទីផ្សារនៃព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែបានបំពេញលក្ខខណ្ឌដូចមានចែងក្នុងមាត្រា១២នៃច្បាប់ស្តីពីការប្រកួតប្រជែង ទោះបីការព្រមព្រៀងឬសកម្មភាពនោះមានប្រភពនៅក្នុងឬក្រៅប្រទេសក៏ដោយ។

**ប្រការ៣.- និយមន័យ**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងសេចក្តីសម្រេចនេះមាននិយមន័យដូចខាងក្រោម៖

១- **បុគ្គលស្នើសុំការអនុញ្ញាតលើកលែង** សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គលស្នើសុំការអនុញ្ញាតលើកលែងពី គ.ប.ក. ចំពោះការព្រមព្រៀងឬសកម្មភាពណាមួយដែលអាចរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែង។

២- **បុគ្គលដែលទទួលបានការអនុញ្ញាតលើកលែង** សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គលដែលទទួលបានការអនុញ្ញាតលើកលែងពី គ.ប.ក. ចំពោះការព្រមព្រៀងឬសកម្មភាពណាមួយដែលអាចរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែង។

៣- **ការអនុញ្ញាតលើកលែង** សំដៅដល់ការអនុញ្ញាតលើកលែងដែលផ្តល់ឱ្យដោយ គ.ប.ក. ដូចមានចែងក្នុងមាត្រា១៣នៃច្បាប់ស្តីពីការប្រកួតប្រជែង ដល់បុគ្គលស្នើសុំការអនុញ្ញាតលើកលែងចំពោះការព្រមព្រៀងឬសកម្មភាពណាមួយដែលអាចរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែង។

## ជំពូកទី២
## ការទទួលបានការអនុញ្ញាតលើកលែង

**ប្រការ៤.- ការស្នើសុំការអនុញ្ញាតលើកលែង**

បុគ្គលដែលយល់ឃើញថា ការព្រមព្រៀងឬសកម្មភាពណាមួយដែលអាចបំពានច្បាប់ដូចមានចែងក្នុងមាត្រា៧ មាត្រា៨ មាត្រា៩ និងមាត្រា១១នៃច្បាប់ស្តីពីការប្រកួតប្រជែង អាចដាក់ពាក្យស្នើសុំការអនុញ្ញាតលើកលែងមក គ.ប.ក. មុនពេលធ្វើការព្រមព្រៀងឬសកម្មភាពនោះ។

ពាក្យស្នើសុំការអនុញ្ញាតលើកលែងចំពោះការព្រមព្រៀងឬសកម្មភាពណាមួយ ដូចមានចែងក្នុងកថាខណ្ឌខាងលើ ត្រូវកំណត់ដោយ គ.ប.ក. ដែលមានអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ "ក.ប.ប." នៃក្រសួងពាណិជ្ជកម្មដែលជាសេនាធិការនិងលេខាធិការដ្ឋានរបស់ គ.ប.ក. ក្នុងការទទួលនិងពិនិត្យលើពាក្យស្នើសុំការអនុញ្ញាតលើកលែងរួមទាំងឯកសារនិងព័ត៌មាននានា ដើម្បីរាយការណ៍ជូន គ.ប.ក. ព្រមទាំងអនុវត្តតួនាទីនិងភារកិច្ចផ្សេងទៀត ស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ៥.- លក្ខខណ្ឌដើម្បីទទួលបានការអនុញ្ញាតលើកលែង**

ដោយអនុលោមតាមមាត្រា១២នៃច្បាប់ស្តីពីការប្រកួតប្រជែង គ.ប.ក. អាចផ្តល់ការអនុញ្ញាតលើកលែង ប្រសិនបើការព្រមព្រៀងឬសកម្មភាពទាំងនោះបំពេញតាមលក្ខខណ្ឌទាំង៤(បួន) ដូចខាងក្រោម៖

១- ផ្តល់នូវអត្ថប្រយោជន៍ផ្នែកបច្ចេកវិទ្យា សង្គម ឬសេដ្ឋកិច្ច គួរឱ្យកត់សម្គាល់ និងអាចកំណត់អត្តសញ្ញាណ ដែលកើតចេញពីការព្រមព្រៀង ឬសកម្មភាពណាមួយដែលបានស្នើឡើង។ អត្ថប្រយោជន៍ទាំងនោះសំដៅដល់ប្រសិទ្ធភាពសេដ្ឋកិច្ច ដែលផ្តោតលើប្រសិទ្ធភាពនៃការចំណាយ (សេដ្ឋកិច្ចមាត្រដ្ឋាន) និងប្រសិទ្ធភាពគុណភាព (ការពង្រឹងគុណភាព ប្រភេទ ឬសេវា ឬការបង្កើតឡើងនូវបច្ចេកវិទ្យាថ្មី វឌ្ឍនភាពនៃបច្ចេកវិទ្យា ឬអត្ថប្រយោជន៍ដល់បរិស្ថាននិងចីរភាព)។

២- អត្ថប្រយោជន៍ខាងលើ នឹងមិនអាចកើតមានឡើង ប្រសិនបើគ្មានការព្រមព្រៀងឬសកម្មភាពដែលបានស្នើឡើង។ ដើម្បីបំពេញតាមលក្ខខណ្ឌនេះ បុគ្គលស្នើសុំការអនុញ្ញាតលើកលែងត្រូវបញ្ជាក់ថា ការរារាំង រឹតត្បិត



១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
លេខទំនាក់ទំនង៖ ១២៦៦
អ៊ីម៉ែល៖ cabinet.info@moc.gov.kh

ឬបង្ខូចដល់ការប្រកួតប្រជែង ដែលកើតចេញពីការព្រមព្រៀងឬសកម្មភាពដែលបានស្នើឡើង មានលក្ខណៈចាំបាច់និងសមហេតុផល ក្នុងការសម្រេចបាននូវអត្ថប្រយោជន៍ទាំងនោះ។ ក្នុងករណីនេះ បុគ្គលស្នើសុំការអនុញ្ញាតលើកលែងត្រូវធានាថា មិនមានវិធីសាស្ត្រ ឬមធ្យោបាយជំនួសណាមួយដែលអាចផ្តល់អត្ថប្រយោជន៍ដូចគ្នា ដោយមិនធ្វើឱ្យប៉ះពាល់លើការប្រកួតប្រជែងនោះឡើយ។

៣- អត្ថប្រយោជន៍ខាងលើមានច្រើនជាងផលប៉ះពាល់ដែលបណ្តាលមកពីការរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែង និងត្រូវកើតឡើងយ៉ាងយូរក្នុងរយៈពេល១(មួយ)ឆ្នាំ។ ក្នុងករណីនេះបុគ្គលស្នើសុំការអនុញ្ញាតលើកលែងត្រូវធានាថា អ្នកប្រើប្រាស់នឹងទទួលបានអត្ថប្រយោជន៍ដែលកើតចេញពីការព្រមព្រៀងឬសកម្មភាពដែលបានស្នើឡើងដោយស្មើភាព។ អត្ថប្រយោជន៍ទាំងនេះ អាចជាការប៉ះប៉ូវដល់អ្នកប្រើប្រាស់សម្រាប់ផលប៉ះពាល់អវិជ្ជមានជាក់ស្តែង ឬអាចបង្កឡើងចំពោះអ្នកប្រើប្រាស់ដោយសារសកម្មភាពដែលរារាំង រឹតត្បិត ឬការបង្ខូចដល់ការប្រកួតប្រជែងណាមួយ។

៤- មិនលុបបំបាត់ការប្រកួតប្រជែងលើផ្នែកសំខាន់ៗណាមួយរបស់ទំនិញឬសេវា។

បុគ្គលស្នើសុំការអនុញ្ញាតលើកលែង ត្រូវបង្ហាញឯកសារនិងព័ត៌មាន ដែលបញ្ជាក់ថា ការព្រមព្រៀងឬសកម្មភាពដែលបានស្នើឡើង បានបំពេញតាមលក្ខខណ្ឌខាងលើដើម្បីទទួលបានការអនុញ្ញាតលើកលែង។

## ជំពូកទី៣
## នីតិវិធីនៃការស្នើសុំការអនុញ្ញាតលើកលែង

**ប្រការ៦.-** ការប្រឹក្សាយោបល់

បុគ្គលដែលមានបំណងស្នើសុំការអនុញ្ញាតលើកលែងពី គ.ប.ក. អាចស្នើសុំការប្រឹក្សាយោបល់ជាមួយអគ្គនាយកដ្ឋាន ក.ប.ប. នៃក្រសួងពាណិជ្ជកម្មដែលជាសេនាធិការនិងលេខាធិការដ្ឋានរបស់ គ.ប.ក. ដើម្បីទទួលបានការពន្យល់ណែនាំអំពីលក្ខខណ្ឌនិងនីតិវិធីសម្រាប់ទទួលបានការអនុញ្ញាតលើកលែង មុនពេលដាក់ពាក្យស្នើសុំមក គ.ប.ក.។

ក្នុងករណីនេះ អគ្គនាយកដ្ឋាន ក.ប.ប. នៃក្រសួងពាណិជ្ជកម្មដែលជាសេនាធិការនិងលេខាធិការដ្ឋានរបស់ គ.ប.ក. អាចបង្ហាញពីភាពទទួលបានការអនុញ្ញាតលើកលែង តាមរយៈការបំពេញលក្ខខណ្ឌដូចមានចែងក្នុងប្រការ៥នៃសេចក្តីសម្រេចនេះ ទៅបុគ្គលស្នើសុំការអនុញ្ញាតលើកលែង ដោយមិនអាចសន្មតជាសេចក្តីសម្រេចចុងក្រោយរបស់ គ.ប.ក. នោះទេ។

ការស្នើសុំប្រឹក្សាយោបល់ត្រូវបង់កម្រៃសេវា ដែលកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

**ប្រការ៧.-** ឯកសារនិងព័ត៌មានសម្រាប់ការដាក់ពាក្យស្នើសុំការអនុញ្ញាតលើកលែង

បុគ្គលស្នើសុំការអនុញ្ញាតលើកលែង ត្រូវផ្តល់នូវឯកសារនិងព័ត៌មាន រួមទាំងភស្តុតាងមក គ.ប.ក. ដោយបញ្ជាក់ថាអាចបំពេញលក្ខខណ្ឌសម្រាប់ស្នើសុំការអនុញ្ញាតលើកលែងដូចមានចែងក្នុងប្រការ៥នៃសេចក្តីសម្រេចនេះ។

ការស្នើសុំការអនុញ្ញាតលើកលែងត្រូវបង់កម្រៃសេវា ដែលកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

**ប្រការ៨.-** ការបញ្ជាក់អំពីភាពគ្រប់គ្រាន់ឬមិនគ្រប់គ្រាន់នៃពាក្យស្នើសុំការអនុញ្ញាតលើកលែង

បន្ទាប់ពីទទួលបានពាក្យស្នើសុំការអនុញ្ញាតលើកលែង គ.ប.ក. មានរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ ដើម្បីចេញសេចក្តីជូនដំណឹងដល់បុគ្គលស្នើសុំការអនុញ្ញាតលើកលែង អំពីភាពគ្រប់គ្រាន់ឬមិនគ្រប់គ្រាន់ ពាក់ព័ន្ធនឹងឯកសារនិងព័ត៌មានដែលបានផ្តល់មក គ.ប.ក.។

ក្នុងករណីឯកសារនិងព័ត៌មានមិនគ្រប់គ្រាន់ បុគ្គលស្នើសុំការអនុញ្ញាតលើកលែងត្រូវផ្តល់ឯកសារនិងព័ត៌មានតម្រូវបន្ថែម តាមកាលបរិច្ឆេទកំណត់ដោយ គ.ប.ក.។ ប្រសិនបើបុគ្គលស្នើសុំការអនុញ្ញាតលើកលែងនោះខកខានក្នុងការផ្តល់ឯកសារនិងព័ត៌មានតម្រូវបន្ថែមតាមកាលបរិច្ឆេទកំណត់នោះទេ ការស្នើសុំការអនុញ្ញាតលើកលែងនោះត្រូវចាត់ទុកជាមោឃៈ។ ក្នុងករណីនេះ បុគ្គលស្នើសុំការអនុញ្ញាតលើកលែង អាចធ្វើការស្នើសុំការអនុញ្ញាតលើកលែងសាជាថ្មីឡើងវិញ។



១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
លេខទំនាក់ទំនង៖ ១២៦៦
អ៊ីម៉ែល៖ cabinet.info@moc.gov.kh

**ប្រការ៩_ ការប្រមូលឯកសារនិងព័ត៌មាន**

បន្ទាប់ពីបញ្ជាក់នូវភាពគ្រប់គ្រាន់ពាក់ព័ន្ធនឹងឯកសារនិងព័ត៌មាន ដែលភ្ជាប់មកជាមួយនឹងពាក្យស្នើសុំការអនុញ្ញាតលើកលែង អគ្គនាយកដ្ឋាន ក.ប.ប. នៃក្រសួងពាណិជ្ជកម្មដែលជាសេនាធិការនិងលេខាធិការដ្ឋានរបស់ គ.ប.ក. ត្រូវស្នើសុំការអនុញ្ញាតពី គ.ប.ក. ដើម្បីចេញសេចក្ដីសង្ខេបអំពីការស្នើសុំការអនុញ្ញាតលើកលែងនៅលើគេហទំព័រ និងបណ្ដាញទំនាក់ទំនងសង្គមផ្លូវការរបស់ខ្លួន ឬមធ្យោបាយផ្សេងទៀតដែលបានកំណត់ដោយ គ.ប.ក. ដោយបញ្ជាក់អំពីថ្ងៃផុតកំណត់សម្រាប់តតិយជន ដែលមានចំណាប់អារម្មណ៍ក្នុងការផ្ដល់មតិយោបល់បន្ថែម។

អគ្គនាយកដ្ឋាន ក.ប.ប. នៃក្រសួងពាណិជ្ជកម្មដែលជាសេនាធិការនិងលេខាធិការដ្ឋានរបស់ គ.ប.ក. ក៏អាចធ្វើការពិគ្រោះយោបល់ជាមួយដៃគូប្រកួតប្រជែង អតិថិជន អ្នកផ្គត់ផ្គង់ ឬអ្នកពាក់ព័ន្ធនឹងបុគ្គលស្នើសុំការអនុញ្ញាតលើកលែងសម្រាប់ផ្ដល់មតិយោបល់លើការស្នើសុំការអនុញ្ញាតលើកលែងនោះ។

**ប្រការ១០_ សេចក្ដីសម្រេចបឋម និងសេចក្ដីសម្រេចចុងក្រោយ**

នៅពេល គ.ប.ក. មានបំណងបដិសេធលើការស្នើសុំការអនុញ្ញាតលើកលែងបន្ទាប់ពីការត្រួតពិនិត្យបឋម គ.ប.ក. ត្រូវចេញសេចក្ដីសម្រេចបឋមទៅបុគ្គលស្នើសុំការអនុញ្ញាតលើកលែង ដោយបញ្ជាក់អំពីមូលហេតុនៃការបដិសេធការស្នើសុំការអនុញ្ញាតលើកលែង ចំពោះការព្រមព្រៀងឬសកម្មភាពដែលបានស្នើឡើង។

ក្នុងករណីនេះ បុគ្គលស្នើសុំការអនុញ្ញាតលើកលែងអាចដាក់សេចក្ដីបញ្ជាក់ការការពារខ្លួន ដើម្បីឆ្លើយតបទៅនឹងសេចក្ដីសម្រេចបឋមតាមកាលបរិច្ឆេទកំណត់ដោយ គ.ប.ក.។

បន្ទាប់ពីទទួលបានសេចក្ដីបញ្ជាក់ការការពារខ្លួនពីបុគ្គលស្នើសុំការអនុញ្ញាតលើកលែង គ.ប.ក. អាចចេញសេចក្ដីជូនដំណឹងទៅបុគ្គលស្នើសុំ ឱ្យបង្ហាញនូវមូលហេតុសំខាន់ៗ និងបញ្ជាក់ពីភាពសមស្របរបស់ខ្លួន តាមទីកន្លែងនិងកាលបរិច្ឆេទកំណត់ដោយ គ.ប.ក.។

គ.ប.ក. អាចស្នើសុំឯកសារនិងព័ត៌មានបន្ថែម មុនចេញសេចក្ដីសម្រេចចុងក្រោយ។

គ.ប.ក. ត្រូវចេញសេចក្ដីសម្រេចចុងក្រោយក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ ហើយអាចពន្យារពេលរហូតដល់ ១០(ដប់)ថ្ងៃនៃថ្ងៃធ្វើការទៀត ដោយមានហេតុផលសមស្រប ដើម្បីចេញសេចក្ដីសម្រេចបញ្ជាក់អំពីការទទួលបានការអនុញ្ញាតលើកលែង ឬបដិសេធការស្នើសុំការអនុញ្ញាតលើកលែង ចំពោះការព្រមព្រៀងឬសកម្មភាពដែលបានស្នើឡើង បន្ទាប់ពីនីតិវិធីខាងលើត្រូវបានបំពេញ។

## ជំពូកទី៤
## លក្ខខណ្ឌនៃការផ្ដល់ការអនុញ្ញាតលើកលែង

**ប្រការ១១_ លក្ខខណ្ឌទូទៅ**

ការអនុញ្ញាតលើកលែងដែលផ្ដល់ដោយ គ.ប.ក. ត្រូវអនុវត្តតាមលក្ខខណ្ឌទូទៅដូចខាងក្រោម៖

១- ការអនុញ្ញាតលើកលែងត្រូវផ្ដល់ឱ្យតែបុគ្គល ដែលទទួលបានការអនុញ្ញាតលើកលែងពាក់ព័ន្ធនឹងការព្រមព្រៀងឬសកម្មភាពណាមួយដែលបានបញ្ជាក់នៅក្នុងការអនុញ្ញាតលើកលែងប៉ុណ្ណោះ។

២- ការអនុញ្ញាតលើកលែងត្រូវផ្ដល់ឱ្យក្នុងរយៈពេលកំណត់ណាមួយ ដែលជាកម្មវត្ថុក្នុងការបន្តសុពលភាព។

៣- បុគ្គលដែលទទួលបានការអនុញ្ញាតលើកលែង ត្រូវបោះបង់ការអនុញ្ញាតលើកលែង បន្ទាប់ពីការព្រមព្រៀងឬសកម្មភាពរបស់ខ្លួនត្រូវបានបញ្ចប់ ឬនៅពេលដែលការអនុញ្ញាតលើកលែង ពុំមានភាពចាំបាច់តទៅទៀត។

៤- ក្នុងបិរវេលាដែលទទួលបានការអនុញ្ញាតលើកលែង រាល់ការផ្លាស់ប្ដូរឈ្មោះ និងព័ត៌មានទំនាក់ទំនងលម្អិតរបស់បុគ្គលដែលទទួលបានការអនុញ្ញាតលើកលែង ត្រូវរាយការណ៍មក គ.ប.ក. ភ្លាមៗ។



១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
លេខទំនាក់ទំនង៖ ១២៦៦
អ៊ីម៉ែល៖ cabinet.info@moc.gov.kh

**ប្រការ១២.-** លក្ខខណ្ឌជាក់លាក់

គ.ប.ក. អាចបញ្ចូលលក្ខខណ្ឌជាក់លាក់ណាមួយនៅក្នុងសេចក្តីសម្រេចចុងក្រោយរបស់ខ្លួនចំពោះការអនុញ្ញាតលើកលែង រួមទាំងការកំណត់លើលក្ខណៈ និងវិសាលភាពនៃការព្រមព្រៀង ឬសកម្មភាពដែលទទួលបានការអនុញ្ញាតលើកលែង និងការការពារដើម្បីកាត់បន្ថយផលប៉ះពាល់ដល់ការប្រកួតប្រជែង។

បុគ្គលដែលទទួលបានការអនុញ្ញាតលើកលែង ត្រូវដាក់របាយការណ៍តាមកាលកំណត់ដែលបានបញ្ជាក់ដោយ គ.ប.ក. រួមទាំងការវាយតម្លៃអំពីភាពចាំបាច់ លក្ខណៈ វិសាលភាព និងការការពារដើម្បីកាត់បន្ថយផលប៉ះពាល់ដល់ការប្រកួតប្រជែង និងការបន្តផ្តល់អត្ថប្រយោជន៍ដល់បច្ចេកវិទ្យា សង្គម ឬសេដ្ឋកិច្ច។

## ជំពូកទី៥
## ការបន្តនិងការកែប្រែការអនុញ្ញាតលើកលែង

**ប្រការ១៣.-** ការបន្តការអនុញ្ញាតលើកលែង

បុគ្គលដែលទទួលបានការអនុញ្ញាតលើកលែង ត្រូវដាក់ពាក្យស្នើសុំមក គ.ប.ក. ដើម្បីបន្តនូវការអនុញ្ញាតលើកលែងដែលទទួលបានមិនលើសពី ៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ មុនពេលផុតសុពលភាពនៃការអនុញ្ញាតលើកលែងនោះ។

ដើម្បីបន្តនូវការអនុញ្ញាតលើកលែង បុគ្គលដែលទទួលបានការអនុញ្ញាតលើកលែងនោះ ត្រូវដាក់ពាក្យស្នើសុំបន្តការអនុញ្ញាតលើកលែងដោយភ្ជាប់នូវឯកសារនិងព័ត៌មានដូចខាងក្រោម៖

១- សេចក្តីបញ្ជាក់អំពីគោលបំណងក្នុងការបន្ត

២- ការផ្លាស់ប្តូរស្ថានភាព និងលក្ខខណ្ឌមួយចំនួន ពីការស្នើសុំការអនុញ្ញាតលើកលែងដែលទទួលបាន

៣- ការទូទាត់កម្រៃសេវាសម្រាប់ការស្នើសុំការអនុញ្ញាតលើកលែងបន្ត។

ពាក្យស្នើសុំបន្តការអនុញ្ញាតលើកលែង ចំពោះការព្រមព្រៀងឬសកម្មភាពណាមួយដូចមានចែងក្នុងកថាខណ្ឌខាងលើត្រូវកំណត់ដោយ គ.ប.ក. ដែលមានអគ្គនាយកដ្ឋាន ក.ប.ប. នៃក្រសួងពាណិជ្ជកម្មដែលជាសេនាធិការនិងលេខាធិការដ្ឋានរបស់ គ.ប.ក. ក្នុងការទទួលនិងពិនិត្យលើពាក្យស្នើសុំការអនុញ្ញាតលើកលែងបន្តរួមទាំងឯកសារនិងព័ត៌មាននានា ដើម្បីរាយការណ៍ជូន គ.ប.ក. ព្រមទាំងអនុវត្តតួនាទីនិងភារកិច្ចផ្សេងទៀត ស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

បន្ទាប់ពីទទួលបានពាក្យស្នើសុំបន្តដែលមានភាពគ្រប់គ្រាន់ គ.ប.ក. ត្រូវវាយតម្លៃអំពីប្រសិទ្ធភាពនិងភាពចាំបាច់ក្នុងការបន្តការអនុញ្ញាតលើកលែងដែលទទួលបាន និងចេញសេចក្តីសម្រេចក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ ហើយអាចពន្យារពេលរហូតដល់ ១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការទៀត ដោយមានមូលហេតុសមស្រប។

ក្នុងករណី គ.ប.ក. មិនបានចេញសេចក្តីសម្រេចស្តីពីការបន្តអនុញ្ញាតលើកលែង មុនពេលផុតសុពលភាព ការអនុញ្ញាតលើកលែងដែលទទួលបាន នឹងបន្តមានសុពលភាពសម្រាប់រយៈពេល ១៨០(មួយរយប៉ែតសិប) ថ្ងៃនៃថ្ងៃប្រតិទិនបន្ថែមទៀត។

ក្នុងករណី គ.ប.ក. មានបំណងបដិសេធលើការស្នើសុំបន្តនេះ គ.ប.ក. ត្រូវធ្វើការជូនដំណឹងទៅបុគ្គលដែលបានស្នើសុំនោះ ឱ្យផ្តល់នូវអំណះអំណាងជាលាយលក្ខណ៍អក្សរមក គ.ប.ក.។

គ.ប.ក. អាចផ្សព្វផ្សាយជាសាធារណៈនូវសេចក្តីសម្រេចនៅលើគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គមផ្លូវការរបស់ខ្លួន ឬមធ្យោបាយផ្សេងទៀតដែលបានកំណត់ដោយ គ.ប.ក. ដោយពិចារណាលើការរក្សាព័ត៌មានដែលមានចរិតលក្ខណៈជាការសម្ងាត់។

**ប្រការ១៤.-** ការបន្ថែមចំនួនបុគ្គលដែលទទួលបានការអនុញ្ញាតលើកលែង

ក្នុងករណីបុគ្គលដែលទទួលបានការអនុញ្ញាតលើកលែង មានបំណងធ្វើការកែសម្រួលនូវវិសាលភាពនៃការអនុញ្ញាតលើកលែងដែលទទួលបាន ដោយរួមបញ្ចូលទាំងការកែប្រែសមាសភាពរូបវន្តបុគ្គល ឬនីតិបុគ្គលនៅក្នុងការ



១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
លេខទំនាក់ទំនង៖ ១២៦៦
អ៊ីម៉ែល៖ cabinet.info@moc.gov.kh

អនុញ្ញាតលើកលែង បុគ្គលនោះត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតលើកលែងសាជាថ្មីមក គ.ប.ក. ស្របតាមនីតិវិធីដូចមានចែងក្នុងសេចក្តីសម្រេចនេះ។

គ.ប.ក. អាចផ្សព្វផ្សាយជាសាធារណៈនូវសេចក្តីសម្រេចនៅលើគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គមផ្លូវការរបស់ខ្លួន ឬមធ្យោបាយផ្សេងទៀតដែលបានកំណត់ដោយ គ.ប.ក. ដោយពិចារណាលើការរក្សាព័ត៌មានដែលមានចរិតលក្ខណៈជាការសម្ងាត់។

**ប្រការ១៥.-** ការបន្តសុពលភាព និងការកែប្រែវិសាលភាព

ការអនុញ្ញាតលើកលែងដែលទទួលបានអាចបន្តសុពលភាពសាជាថ្មី ឬអាចកែប្រែនូវវិសាលភាពនៃការអនុញ្ញាតលើកលែងដែលទទួលបាន ប្រសិនបើបុគ្គលដែលទទួលបានការលើកលែងអាចបង្ហាញថាការអនុញ្ញាតលើកលែងដែលស្នើសុំ បានអនុវត្តស្របតាមគោលបំណងដូចបានកំណត់ក្នុងការអនុញ្ញាតលើកលែងដែលទទួលបាន ដោយភ្ជាប់ជាមួយឯកសារនិងព័ត៌មានសម្រាប់គាំទ្រ។

## ជំពូកទី៦
## ការកែប្រែ ឬការលុបចោលសេចក្តីសម្រេចការអនុញ្ញាតលើកលែង

**ប្រការ១៦.-** ហេតុផលនៃការកែប្រែ ឬការលុបចោលសេចក្តីសម្រេចការអនុញ្ញាតលើកលែង

គ.ប.ក. អាចកែប្រែ ឬលុបចោលសេចក្តីសម្រេចការអនុញ្ញាតលើកលែងដែលទទួលបាន ក្នុងករណីជាអាទិ៍៖

១- បុគ្គលដែលទទួលបានការអនុញ្ញាតលើកលែង ផ្តល់នូវឯកសារនិងព័ត៌មានដែលក្លែងបន្លំ មិនពិត ឬបំភាន់ដល់ គ.ប.ក. ដើម្បីទទួលបានការអនុញ្ញាតលើកលែង ការបន្តការអនុញ្ញាតលើកលែងសាជាថ្មី និងការកែប្រែវិសាលភាពនៃការអនុញ្ញាតលើកលែង ឬក្នុងរបាយការណ៍តាមកាលកំណត់មក គ.ប.ក.

២- បុគ្គលដែលទទួលបានការអនុញ្ញាតលើកលែងមិនអនុលោមតាមលក្ខខណ្ឌដូចបានកំណត់ដោយ គ.ប.ក. ក្នុងការអនុញ្ញាតលើកលែងដែលទទួលបាន ឬ

៣- បុគ្គលដែលទទួលបានការអនុញ្ញាតលើកលែងមិនបានបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៥នៃសេចក្តីសម្រេចនេះ។

ការអនុញ្ញាតលើកលែងដែលទទួលបាន បន្តមានសុពលភាពរហូតដល់ គ.ប.ក. ចេញសេចក្តីសម្រេចចុងក្រោយលើការកែប្រែ ឬការលុបចោលការអនុញ្ញាតលើកលែង។

**ប្រការ១៧.-** ដំណើរការការកែប្រែ ឬការលុបចោលការអនុញ្ញាតលើកលែង

ក្នុងករណី គ.ប.ក. មានហេតុផលសមស្របក្នុងការកែប្រែ ឬការលុបចោលនូវការអនុញ្ញាតលើកលែងណាមួយ គ.ប.ក. ត្រូវចេញសេចក្តីជូនដំណឹងដល់បុគ្គលដែលទទួលបានការអនុញ្ញាតលើកលែង។

សេចក្តីសម្រេចចុងក្រោយលើការកែប្រែ ឬការលុបចោលការអនុញ្ញាតលើកលែងត្រូវអនុវត្តតាមនីតិវិធីដូចមានចែងក្នុងប្រការ១០នៃសេចក្តីសម្រេចនេះ។

## ជំពូកទី៧
## ការចាត់វិធានការ និងការរក្សាព័ត៌មានសម្ងាត់

**ប្រការ១៨.-** ការចាត់វិធានការ

គ.ប.ក. ត្រូវចាត់វិធានការ ចំពោះបុគ្គលដែលទទួលបានការអនុញ្ញាតលើកលែង ក្នុងករណីដូចខាងក្រោម៖

១- បុគ្គលនោះមិនអនុវត្តតាមលក្ខខណ្ឌដូចមានចែងក្នុងការអនុញ្ញាតលើកលែងរបស់ គ.ប.ក.

២- បុគ្គលនោះអនុវត្តការព្រមព្រៀងឬសកម្មភាពដែលមិនស្ថិតនៅក្រោមវិសាលភាពនៃការអនុញ្ញាតលើកលែង ដោយរួមបញ្ចូលទាំងការព្រមព្រៀងឬសកម្មភាពដែលត្រូវបានហាមឃាត់ និងមិនទទួលបានការអនុញ្ញាតលើកលែង ឬ



១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
លេខទំនាក់ទំនង៖ ១២៦៦
អ៊ីម៉ែល៖ cabinet.info@moc.gov.kh

៣- មូលហេតុផ្សេងទៀតដែលកំណត់ដោយ គ.ប.ក. ក្នុងការកែប្រែ ឬការលុបចោលនូវការអនុញ្ញាតលើកលែង។

វិធានការខាងលើអាចរាប់បញ្ចូលទាំងការតម្រូវឱ្យបុគ្គលដែលទទួលបានការអនុញ្ញាតលើកលែង បញ្ឈប់រាល់សកម្មភាពបំពានច្បាប់ ឬការតម្រូវផ្សេងៗទៀត ដូចមានចែងក្នុងមាត្រា៣៧នៃច្បាប់ស្តីពីការប្រកួតប្រជែង។ ការចាត់វិធានការទាំងនេះមិនរារាំងដល់ គ.ប.ក. ក្នុងការអនុវត្តច្បាប់ស្តីពីការប្រកួតប្រជែង និងបទប្បញ្ញត្តិជាធរមានផ្សេងទៀតឡើយ។

**ប្រការ១៩.-** ការរក្សាព័ត៌មានសម្ងាត់

គ.ប.ក. មិនត្រូវលាតត្រដាងព័ត៌មានដែលមានចរិតលក្ខណៈជាការសម្ងាត់ លើកលែងតែការលាតត្រដាងនោះត្រូវបានធ្វើឡើង ដោយអនុលោមតាមមាត្រា២៣នៃច្បាប់ស្តីពីការប្រកួតប្រជែង។

គ.ប.ក. អាចផ្សព្វផ្សាយជាសាធារណៈនូវសេចក្តីសម្រេចនៅលើគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គមផ្លូវការរបស់ខ្លួន ឬមធ្យោបាយផ្សេងទៀតដែលបានកំណត់ដោយ គ.ប.ក. ដោយពិចារណាលើការរក្សាព័ត៌មានសម្ងាត់។ បុគ្គលស្នើសុំការអនុញ្ញាតលើកលែង ត្រូវបញ្ជាក់ឯកសារនិងព័ត៌មានដែលមានចរិតលក្ខណៈជាការសម្ងាត់មក គ.ប.ក. នៅពេលដាក់ពាក្យស្នើសុំការអនុញ្ញាតលើកលែងដោយ៖

១- បញ្ជាក់យ៉ាងច្បាស់នូវឯកសារនិងព័ត៌មានណាមួយដែលមានចរិតលក្ខណៈជាការសម្ងាត់

២- ផ្តល់នូវមូលហេតុសម្រាប់ការរក្សាឯកសារនិងព័ត៌មានដែលមានចរិតលក្ខណៈជាការសម្ងាត់ និង

៣- ផ្តល់នូវឯកសារនិងព័ត៌មានមួយច្បាប់ដោយឡែក ដែលមិនផ្ទុកនូវឯកសារនិងព័ត៌មានដែលមានចរិតលក្ខណៈជាការសម្ងាត់។

## ជំពូកទី៨
## អវសានប្បញ្ញត្តិ

**ប្រការ២០.-** និរាករណ៍

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ២១.-** ការអនុវត្ត

សមាសភាពគណៈកម្មាធិការប្រកួតប្រជែងកម្ពុជា នាយកខុទ្ទកាល័យ ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៨រោច ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២ ខែមេសា ឆ្នាំ២០២៤

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**និងជាប្រធានគណៈកម្មាធិការប្រកួតប្រជែងកម្ពុជា**

**ចម និម្មល**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ២១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
លេខទំនាក់ទំនង៖ ១២៦៦
អ៊ីម៉ែល៖ cabinet.info@moc.gov.kh